អង្គរបុរី

សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ ក្រោមប្រធានបទ ធម៌ដែលនាំឲ្យព្រះសង្ឃសាមគ្គីគ្នាក្នុងផ្លូវពុទ្ធចក្រ និងធម៌ដែលនាំឲ្យគ្រហស្ថសាមគ្គីគ្នាក្នុងផ្លូវអាណាចក្រ

website : www.hoksavann.org

ថ្ងៃទី២៨ មេសា ២០០៧



ពុទ្ធភាសិតថា សាមគ្គី សាមគ្គានំ តបោ សុខោ ប្រែថា ការព្រមព្រៀងគ្នារបស់អ្នកព្រមព្រៀងគ្នាទាំងឡាយ ជាតបធម៌នាំឲ្យមានសេចក្ដីសុខ ។ មានអត្ថន័យថា សង្គមណាក៏ដោយ បើមានការព្រមព្រៀងគ្នាដោយកាយវាចាចិត្តហើយ សង្គមនោះរមែងបាននូវសេចក្ដីសុខ ។ មូលហេតុដែលនាំឲ្យកើតសាមគ្គី សូមលើកយកតែធម៌មួយជាចំបង គឺបើព្រះសង្ឃគោរពព្រះវិន័យ បើគ្រហស្ថគោរពច្បាប់ជាតិនិងអន្តរជាតិ នោះសាមគ្គីរមែងកើតមាន ។

ចំពោះព្រះសង្ឃព្រះពុទ្ធសាសនា ព្រះពុទ្ធបានបញ្ញត្តិព្រះវិន័យទុកជាក្បួនខ្នាត សំរាប់ព្រះសង្ឃគ្រប់ព្រះអង្គប្រតិបត្តិតាម ដើម្បីសេចក្ដីបរិសុទ្ធក្នុងសង្គមរបស់ព្រះសង្ឃ បើព្រះសង្ឃបរិសុទ្ធគ្រប់អង្គហើយ សាមគ្គីរមែងកើតមាន កាលណាបើមានសាមគ្គីហើយ សេចក្ដីសុខរមែងកើតមាន ។ ផ្ទុយទៅវិញ ព្រះសង្ឃបរិសុទ្ធនិងមិនសាមគ្គីជាមួយព្រះសង្ឃមិនបរិសុទ្ធ មិនគោរពព្រះវិន័យ មានធ្វើសង្ឃកម្មជាមួយគ្នាឡើយ ។ បើព្រះសង្ឃគ្រប់វត្តក្នុងប្រទេសកម្ពុជាគោរពព្រះវិន័យ នោះសាមគ្គីរបស់ព្រះសង្ឃរមែងកើតមានទូទាំងប្រទេសដែរ ។ ព្រោះព្រះវិន័យ ។ ព្រះសង្ឃបរិសុទ្ធពុំអាចធ្វើសង្ឃកម្មជាមួយព្រះសង្ឃមានកំហុស ឬមានកំហុសហើយពុំបានសំអាចឲ្យបរិសុទ្ធ ។ ដូច្នេះបញ្ជាក់ថា សាមគ្គីធ្វើសង្ឃកម្មជាមួយគ្នារបស់ព្រះសង្ឃ កើតឡើងដោយព្រះសង្ឃគោរពព្រះវិន័យដូចគ្នា ។ កិច្ចការរបស់ព្រះសង្ឃដែលហៅថាសង្ឃកម្មមានច្រើន ដែលព្រះសង្ឃក្នុងព្រះពុទ្ធសា

សនាត្រូវព្រមព្រៀងគ្នាធ្វើ ដូចជាធ្វើឧបោសថសំដែងបាតិមោក្ខ ធ្វើកឋិនកម្ម បវារណាកម្មជាដើម ។ ពេលមានកិច្ចប្រជុំ ត្រូវព្រមព្រៀងគ្នាប្រជុំ និងព្រមព្រៀងគ្នាក្រោកចាកការប្រជុំជាដើម ។ ដូច្នេះបើព្រះសង្ឃទាំងអស់អង្គគោរពព្រះវិន័យ សាមគ្គីរមែងកើតមានឡើង ។

ចំណែកគ្រហស្ថផ្លូវអាណាចក្រវិញ មូលហេតុដែលនាំឲ្យមានសាមគ្គី គឺកើតឡើងពីការគោរពច្បាប់របស់ប្រទេសនិងច្បាប់អន្តរជាតិ ។ បានសេចក្ដីថា ទាំងប្រជាពលរដ្ឋ ទាំងអ្នករដ្ឋការគ្រប់តំណែង ពីថ្នាក់លើថ្នាក់ក្រោមបានគោរពច្បាប់ទាំងអស់គ្នា នោះសាមគ្គីរមែងកើតមាន ព្រោះមានការទុកចិត្តគ្នា ដោយទាំងអស់គ្នាស្ថិតនៅក្រោមអំណាចច្បាប់ ។ បើមានបញ្ហាអ្វីមួយកើតឡើង តុលាការកាត់សេចក្ដីប្រកបដោយគតិយុត្តិធម៌ពុំលំអៀង ។ ច្បាប់របស់ប្រទេសនីមួយៗ ដែលតាក់តែងឡើងសំរាប់គោរពទាំងអស់គ្នា ។ បើច្បាប់នោះគោរពតែប្រជាពលរដ្ឋ អ្នករដ្ឋការពុំគោរពឬគោរពតែអ្នករដ្ឋការថ្នាក់ក្រោម ចំណែកអ្នករដ្ឋការថ្នាក់មិនគោរព ច្បាប់នោះពុំមានប្រសិទ្ធិភាពឡើយ ។ ជាពិសេសប្រទេសមួយ បើគ្មានយុត្តិធម៌ក្នុងសង្គមទេ ការបែកបាក់គ្នារមែងកើតមាន ។ បានសេចក្ដីថា មនុស្សល្អគោរពច្បាប់មិនអាចទៅរួមជាមួយមនុស្សអាក្រក់មិនគោរពច្បាប់ឡើយ គឺមនុស្សល្អមិនធ្វើចោរ មិនអាចទៅរួមជាមួយមនុស្សអាក្រក់លួចប្លន់ឡើយ ។ ឧទាហរណ៍នៅប្រទេសកម្ពុជា ប្រជាពលរដ្ឋខ្មែរដែលនៅសល់ពីស្លាប់ ដោយអំពើឧក្រិដ្ឋកម្មរបស់ពួកខ្មែរក្រហម មិនជឿទុកចិត្តខ្មែរក្រហមដែលបានធ្វើបាបខ្លួនឡើយ ។ កាលណាមិនជឿទុកចិត្ត ការសាមគ្គីជាមួយខ្មែរក្រហមក៏ពុំអាចកើតមានឡើយ ។ ប្រជាពលរដ្ឋខ្មែរ មិនរួមជាមួយជនពុករលួយរំលោភច្បាប់ ធ្វើឲ្យខូចប្រយោជន៍ជាតិឡើយ ដូចច្បាប់ហាមមិនឲ្យកាប់ព្រៃឈើ ជនពុករលួយកាប់ព្រៃឈើស្ទើរពាយស្រុកខ្មែរ ។ ច្បាប់ហាមមិនឲ្យរំលោភដីរដ្ឋនិងដីរបស់ប្រជាពលរដ្ឋ ជនអ្នកមានអំណាចបានរំលោភយកដោយគ្មានខ្លាចរអែង ។ ការអនុវត្តន៍ច្បាប់ពុំបានត្រឹមត្រូវ បានបង្កើតនូវអំពើអយុត្តិធម៌ក្នុងសង្គមដែលធ្វើឲ្យអ្នកមាននិងអ្នកក្រមានគំលាតគ្នាកាន់តែឆ្ងាយទៅៗ ។ ការនេះបានប៉ះពាល់ដល់អ្នកក្រីក្រ ដែលរកមិនមួយដុល្លារក្នុងមួយថ្ងៃ ហើយអ្នករដ្ឋការតូចតាចបានប្រាក់បៀវត្សតិចស្ទើរតែមិនអាចរស់បាន ។ បញ្ហាព្រំដែនដីគោកនិងដីសមុទ្រមានភាពមិនប្រក្រតី បញ្ហាជនអន្តោប្រវេសន៍វៀតណាមចូលមកកម្ពុជាដោយខុសច្បាប់ រាជរដ្ឋាភិបាលមិនព្រមដោះស្រាយ ទាំងនេះមិនអាចឲ្យប្រជាពលរដ្ឋខ្មែរ ស្រុះស្រួលចិត្តគំនិតរួមសាមគ្គីជាមួយអ្នកដឹកនាំរបស់ខ្លួនឡើយ ។ នៅប្រទេសដែលកាន់របបប្រជាធិបតេយ្យ អ្នកដឹកនាំគេសុខចិត្តលាចេញពីតំណែង បើគេដឹងខ្លួនគេថាមិនអាចដោះស្រាយបញ្ហាជាតិពេលនេះបានទេ ដើម្បីទុកឱកាសឲ្យអ្នកមានសមត្ថភាពដោះស្រាយបន្ត មិនទុកឲ្យវិបត្តិកាន់តែធ្ងន់ឡើងខូចប្រយោជន៍ជាតិឡើយ ហើយបើគេមិនប្រើអំពើហិង្សាបង្ក្រាបចំពោះអ្នកប្រឆាំង ដើម្បីដោះស្រាយបញ្ហាទាល់ច្រក

របស់ខ្លួន ឬគេចវេះមិនដោះស្រាយឡើយ ព្រោះនេះជាអំពើរំលោភច្បាប់ ។ ដូច្នេះ ការគោរពច្បាប់ជាកត្តាចំបងទីមួយឆ្ពោះទៅរកសាមគ្គីភាពនៃសង្គមប្រជាធិបតេយ្យ ។ ក៏ដូចជាព្រះសង្ឃគោរពព្រះវិន័យ ជាកត្តានាំឲ្យមានសាមគ្គី រវាងព្រះសង្ឃនិងព្រះសង្ឃដូចនេះដែរ ។៚